អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

## អ.វ.ត.ក សហការជាមួយប្រព័ន្ធសារព័ត៌មាន ផ្សព្វផ្សាយឯកសារចងក្រង សេចក្តីសុំអភ័យទោសរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច

ដើម្បីឲ្យឯកសារចងក្រងអំពីការទទួលស្គាល់កំហុសនិងសេចក្តីសុំអភ័យទោសរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានផ្សព្វផ្សាយដល់សាធារណជនកម្ពុជា ផ្នែកកិច្ចការសាធារណៈនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានចាប់ផ្តើមកិច្ចសហប្រតិបត្តិការជាមួយកាសែតមួយចំនួន សារព័ត៌មានតាមអ៊ិនធឺណែត វិទ្យុ និងទូរទស្សន៍ ដើម្បីផ្សព្វផ្សាយដោយឥតគិតថ្លៃ នូវឯកសារចងក្រងស្តីអំពីការទទួលស្គាល់កំហុសនិងសេចក្តីសុំអភ័យទោស ដោយពេញលេញឬដោយសង្ខេប។

ការចែកផ្សាយឯកសារនេះធ្វើឡើងបន្ទាប់ពីការប្រកាសសាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ នៅក្នុងនោះ អង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលរៀបចំឲ្យមានការចងក្រងនិងផ្សព្វផ្សាយនៅលើគេហទំព័ររបស់ អ.វ.ត.ក នូវសេចក្តីទទួលស្គាល់កំហុសនិងសុំអភ័យទោសរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច នៅក្នុងអំឡុងពេលសវនាការ បូករួមទាំងសវនាការលើបណ្តឹងឧទ្ធរណ៍ផង។

នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១២ សារព័ត៌មានប្រចាំថ្ងៃ ដើមអំពិល និងកម្ពុជាថ្មី បានចាប់ផ្តើមបោះពុម្ពផ្សាយផ្នែកដំបូងនៃសេចក្តីសុំអភ័យទោស ហើយនឹងបន្តបោះពុម្ពផ្នែកដែលនៅសេសសល់ជាបន្តបន្ទាប់ទៀត។

សារព័ត៌មានតាមអ៊ីនធឺណិតមួយចំនួន ដូចជា ខេមបូឌា អិចប្រេស ញូវ និង ដើមអំពិល ញូវ ក៏បានផ្សាយទាំងស្រុងនូវសេចក្តីសុំអភ័យទោសនេះ ហើយស្ថានីយ៍ទូរទស្សន៍អប្សរា បាយ័ន និងហង្សមាស ក៏បានចាប់ផ្តើមចាក់ផ្សាយសេចក្តីសុំអភ័យទោសជាសំឡេងនិងជាវីដេអូ។

សារព័ត៌មានប្រចាំថ្ងៃចំនួន៣ទៀត គឺសារព័ត៌មានរស្មីកម្ពុជា ភ្នំពេញប៉ុស្តិ៍ភាសាខ្មែរ និងកោះសន្តិភាព ក៏នឹងបោះពុម្ពផ្សាយសេចក្តីសង្ខេបនៃសេចក្តីសុំអភ័យទោសនេះនៅថ្ងៃខាងមុខទៀតដែរ។

នៅពេលឆាប់ៗខាងមុខ អង្គភាពគាំពារជនរងគ្រោះនិងផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក ក៏នឹងចែកចាយឯកសារនេះក្នុងទម្រង់ជាសៀវភៅ។ ឯកសារសុំអភ័យទោសជាវីដេអូនិងជាសំឡេងក៏នឹងត្រូវយកទៅចាក់បញ្ចាំងជូនប្រជាពលរដ្ឋនៅតាមបណ្តាខេត្តនានា តាមរយៈកម្មវិធី *រាត្រីនៃការចងចាំ* របស់ផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក។ កិច្ចការនេះនឹងចាប់ផ្តើមពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១២នេះ នៅខេត្តកំពង់ធំ ដែលជាខេត្តកំណើតរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច។

ឯកសារចងក្រងនេះក៏អាចទាញយកបានពីគេហទំព័ររបស់ អ.វ.ត.ក តាមអាសយដ្ឋានខាងក្រោម៖
http://www.eccc.gov.kh/document/court/16800

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទចល័ត: +៨៥៥ (០) ១២ ៤៨៨ ០២៣
ទូរស័ព្ទ: +៨៥៥(០) ២៣ ៨១៤ លេខបន្ត: ៦១៦៩
សារអេឡិកត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
អ្នកនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ: +៨៥៥-១២ ៤៨ ៣២៨៣
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh